**អង្គរបុរី**
**សម្លេងខ្មែរនៅបរទេស**

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ គុណមាតាបិតា ប្រៀបមកគុណ ព្រះពុទ្ធព្រះបរមគ្រូ ។

website: www.hoksavann.org
ថ្ងៃទី២២ មីនា ២០០៨



អ្នកកាន់ព្រះពុទ្ធសាសនាខ្លះចង់ដឹងថា គុណមាតាបិតានិងគុណព្រះសម្មាសម្ពុទ្ធ មានលក្ខណៈប្លែកគ្នាបែបណា ។ ជាដំបូងគប្បីយល់អំពីពាក្យថាគុណ ។ ពាក្យគុណជាភាសាបាលី ដែលប្រែជាភាសាខ្មែរថា សេចក្តីល្អរបស់បុគ្គលណាម្នាក់ ។ ដូចពាក្យថាបុគ្គលនេះមានគុណធម៌ ឬគុណសម្បត្តិល្អគួរសេពគប់ ។ ឧទាហរណ៍សាមញ្ញដូចបុគ្គលណាម្នាក់ បានឲ្យវត្ថុអ្វីមួយដល់បុគ្គលណាម្នាក់ បុគ្គលដែលបានទទួលអំណោយពោលថា សូមអរគុណ ។ គុណក្នុងទីនេះ សំដៅយកសេចក្តីល្អ ដែលបុគ្គលនោះលះវត្ថុធ្វើជាទាន ។ ពាក្យគុណនេះមានលក្ខណៈស្មើគ្នានឹងពាក្យថាបុណ្យកុសលសុចរិត អំពើល្អ ។

ចំពោះគុណដែលមាតាបិតាមានចំពោះកូនប្រុសស្រី គឺនៅត្រង់គាត់ចិញ្ចឹមបីបាច់រក្សាកូនប្រុសស្រីឲ្យរស់រានមានជីវិត បង្រៀនឲ្យចេះនិយាយស្តី បញ្ជូនកូនឲ្យទៅសិក្សារៀនសូត្រ អប់រំកូនឲ្យប្រព្រឹត្តអំពើល្អ ចែកមត៌កឲ្យកូនធ្វើជាដើមទុនសំរាប់រកស៊ីជាដើម ។ ការបញ្ចេញជាសង្គហធម៌សង្គ្រោះនេះឡើង ដោយសារមាតាបិតាមានទឹកចិត្តប្រកបដោយព្រហ្មវិហារធម៌ គឺមេត្តាករុណា និង ឧបេក្ខា ។ គាត់មានទឹកចិត្តស្រឡាញ់រាប់អានកូនចាប់តាំងពីគាត់ដឹងថា កូនមកចាប់បដិសន្ធិហើយ ។ គាត់មានចិត្តអាណិតអាសូរកូន ពេលដែលកូនមានទុក្ខ ហើយខំប្រឹងប្រែងដោះស្រាយ ដូចជាកូនមានជម្ងឺ ខំបន់ស្រន់ឲ្យកូនឆាប់ជា, យកកូនទៅមន្ទីរពេទ្យព្យាបាលជម្ងឺ ។ ពេលកូនមានសុខភាពល្អ បានសុខកាយសប្បាយចិត្ត ម្តាយឪពុកមានចិត្តសប្បាយរីករាយយ៉ាងក្រៃលែង ។ ម្តាយឪពុកបានធូរស្រាលពីបន្ទុកខ្លួន ដោយសារកូនធំពេញរូបរាង ចេះទទួលខុសត្រូវក្នុងការរស់នៅរប

ស់ខ្លួនបានហើយ ។ សកម្មភាពជាគុណធម៌ ឬជាអំពើល្អរបស់គាត់មកលើបុត្រធីតាប្រុសស្រីនេះហើយ ដែលហៅថាគុណ ។ គេមិនអាចបដិសេធថា គាត់គ្មានគុណឡើយ ។ បើបដិសេធថាគាត់គ្មានគុណ ក៏ដូចជាបដិសេធអំពើល្អរបស់គាត់មកលើកូនប្រុសស្រី ដូចពោលមកហើយដូច្នោះដែរ ។ បើទទួលដឹងថា សកម្មភាពល្អរបស់គាត់មកលើកូនប្រុសស្រីមានពិតមែន នោះហើយជាការទទួលស្គាល់គុណរបស់គាត់ទាំងពីរ ។ មានខ្លះពោលថា គាត់សប្បាយគ្នាគាត់ក៏កើតយើងមក ដូច្នេះគាត់គ្មានគុណអ្វីទេ ។ ដូចបានពោលមកហើយ គុណនៅត្រង់គាត់ចិញ្ចឹមកូនឲ្យរស់ បើគេសួរថាកូនកើតមកពីណា មុខជាឆ្លើយថាខ្ញុំកើតមកពីអ្នកនោះ ចុះអ្នកនោះធ្វើដូចម្ដេចទើបខ្លួនរស់ មុខជារកឃើញថា អ្នកដែលបង្កើតហើយចិញ្ចឹមខ្លួនឲ្យរស់នោះហើយ ជាអ្នកមានគុណ ត្រង់គាត់សប្បាយគ្នាគាត់ ឬមិនសប្បាយជារឿងផ្សេង មិនទាក់ទងនឹងការចិញ្ចឹមនេះឡើយ ។ មួយទៀត មានពាហិន-សាសនា គឺសាសនាដទៃក្រៅពីព្រះពុទ្ធសាសនាពោលថា ម្ដាយឪពុកគ្មានគុណលើកូនប្រុសស្រីទេ អ្នកដែលមានគុណគឺព្រះអាទិទេព ជាព្រះបង្កើតលោកវិញទេ ។ នេះជាទ-ស្សនៈគ្មានហេតុផល តើអ្នកណាបានឃើញព្រះបង្កើតលោក ។ ព្រះពុទ្ធសាសនាសំដែងថា អវិជ្ជា តណ្ហា ឧបាទាន និងកម្ម ជាតួសភាវធម៌ ជាហេតុ ជាបច្ច័យនាំឲ្យកើតមនុស្សសត្វ ។ ការកើតឡើងជាហេតុនាំឲ្យមានទុក្ខ ដូច្នេះដើម្បីបំបាត់ទុក្ខ ត្រូវលះបង់ ឬសម្លាប់ហេតុដែលនាំឲ្យមានទុក្ខ គឺសម្លាប់អវិជ្ជា និងតណ្ហានេះឯង ។ បើព្រះអាទិទេពបង្កើតមនុស្សសត្វ ដូច្នេះព្រះអាទិទេពជាមេដែលបណ្ដាលឲ្យមនុស្សសត្វមានទុក្ខ តើត្រូវធ្វើដូចម្ដេចដើម្បីឲ្យមនុស្សសត្វអស់ទុក្ខ ។ បើព្រះអាទិទេពគង់នៅ ព្រះអង្គនៅតែបង្កើតជាតិឲ្យមនុស្សសត្វមានទុក្ខតទៅទៀត មានជរាទុក្ខ មរណទុក្ខជាដើម ។ ចំណែកម្ដាយឪពុកពុំមែនជាហេតុបង្កើតជាតិដល់កូនឡើយ កូនមកចាប់បដិសន្ធិទៅតាមកម្មផលរបស់កូន ម្ដាយឪពុកគ្រាន់តែពផ្ទៃ ហើយចិញ្ចឹមកូនឲ្យរស់ប៉ុណ្ណោះ ។ ការចិញ្ចឹមកូនឲ្យរស់នេះហើយ ដែលគាត់ជាអ្នកមានគុណ ។

ចំណែកគុណរបស់ព្រះពុទ្ធ នៅក្នុងពុទ្ធគុណក្នុងព្រះនាមទាំង៩ មានព្រះនាមថាអរហំជាដើម ដោយសង្ខេបមានបីគឺ វិសុទ្ធិគុណ បញ្ញាគុណ និងករុណាគុណ ។ វិសុទ្ធិគុណប្រែថាគុណគឺសេចក្ដីបរិសុទ្ធ ។ មានសេចក្ដីថា ព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេស គ្រឿងសៅហ្មងចិត្តអស់ហើយ ។ ព្រះអង្គជាបុគ្គលបរិសុទ្ធ មិនធ្វើអំពើបាបគ្រប់យ៉ាង ទាំងទីកំបាំងមុខ ទាំងចំពោះមុខ ។ បញ្ញាគុណប្រែថា គុណគឺបញ្ញា ។ មានសេចក្ដីថា ព្រះអង្គត្រាស់ដឹងអរិយសច្ច៤ ជាធម៌ចេញចាកទុក្ខ ។ បញ្ញាដែលព្រះអង្គត្រាស់ដឹងនេះ ជាលោកុត្តរបញ្ញា ជាបញ្ញាចេញចាកលោក ពុំមែនជាលោកិយបញ្ញាឡើយ ។ ករុណាគុណប្រែថា គុណគឺករុណា ។ ករុណាប្រែថា ការអាណិតអាសូរមនុស្សសត្វរបស់ព្រះអង្គ ដែលកំពុងវិលកើតវិលស្លាប់ក្នុងសង្សារវដ្ដ ។

ព្រះអង្គបានសំដែងព្រះធម៌ប្រោសសត្វ ឲ្យមនុស្សសត្វយកទៅប្រតិបត្តិតាម ដើម្បីឲ្យបានសំរេចព្រះនិពាន្វជាការរំលត់ទុក្ខ ។

បើប្រៀបធៀបគុណមាតាបិតា និងគុណព្រះពុទ្ធ មានលក្ខណៈខុសគ្នា ។ វិសិទ្ធិគុណ និងបញ្ញាគុណ ជាសេចក្តីបរិសុទ្ធ និងបញ្ញាផ្ទាល់ខ្លួនព្រះអង្គ ចំណែកមាតាបិតាគុណនេះគ្មានទេ ។ ករុណាគុណ ព្រះអង្គសំដែងធម៌ប្រោសមនុស្សសត្វ ឲ្យយកទៅប្រតិបត្តិតាម រហូតចាកចេញទុក្ខ ចំណែកមាតាបិតាជួយសង្គ្រោះកូនប្រុសស្រីឲ្យបានសុខស្រួលតែក្នុងជីវភាពបច្ចុប្បន្នប៉ុណ្ណោះ ។ ដូច្នេះបញ្ជាក់ថា ព្រះពុទ្ធមានគុណពិសេសដ៏ខ្ពង់ខ្ពស់ជាងគុណមាតាបិតា ។ល៕

❄ ❄

❄